# អនុក្រឹត្យ

# ស្តីពី

# មូលនិធិឃុំ សង្កាត់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី មូលនិធិឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូឆ្នាំ២០០១ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងតាមស្មារតីអង្គប្រជុំលើកទី៨របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ បែបបទ នីតិវិធី នៃការគ្រប់គ្រងមូលនិធិឃុំ សង្កាត់ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ មូលនិធិឃុំ សង្កាត់ហៅកាត់ថា " មូលនិធិ " ។

**មាត្រា ២.-**

មូលនិធិមានគោលបំណង ដូចខាងក្រោម:

- ធ្វើអោយឃុំ សង្កាត់ អាចរ៉ាប់រងការទទួលខុសត្រូវជាទូទៅ លើការងាររដ្ឋបាលមូលដ្ឋាន និងជំរុញកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋានស្របទៅនឹងមាត្រា៤២ មាត្រា៤៣ និង មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- កាត់បន្ថយភាពខុសគ្នាអំពី សក្តានុពលក្នុងការប្រមូលចំណូលផ្ទាល់រវាងឃុំ សង្កាត់នានា ដោយសារស្ថានភាពអាចនឹងផ្សេងគ្នា លើល័ក្ខខ័ណ្ឌភូមិសាស្រ្ត សេដ្ឋកិច្ច សង្គម និង ប្រជាសាស្រ្ត
- ជួយលើកទឹកចិត្តដល់ការកសាងសមត្ថភាពសំរាប់ការងារអភិបាលកិច្ចល្អរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣.-**

គណនីមូលនិធិឃុំ សង្កាត់ត្រូវបើកនៅរតនាគារជាតិ ។

គណនីមូលនិធិឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំង:

ក-ផ្នែកចំណូល:

- ការចូលរួមមួយចំណែក ពីចំណូលចរន្តនៃថវិការដ្ឋ
- ការចូលរួមពីជំនួយឥតសំណង និងការខ្ចីដែលបានមកពីម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា
- ការចូលរួមពីប្រភពផ្សេងៗទៀត ។

ខ-ផ្នែកចំណាយ:

- ការផ្ទេរប្រចាំឆ្នាំ ទៅក្នុងថវិកាឃុំ សង្កាត់

ចំណូលនៃមូលនិធិទាំងឡាយណាដែលមិនបានផ្ទេរក្នុងឆ្នាំ ត្រូវយោងទៅឆ្នាំបន្ទាប់ ។

### ជំពូកទី ២
### ការគ្រប់គ្រងមូលនិធិឃុំ សង្កាត់

**មាត្រា ៤.-**

ក្រុមប្រឹក្សាភិបាលមួយត្រូវបានបង្កើតឡើង ដោយអោយឈ្មោះថា ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ហៅកាត់ថា "ក្រុមប្រឹក្សាភិបាលមូលនិធិ" ។

-2-

ក្រុមប្រឹក្សាភិបាលមូលនិធិនេះ មានភារៈទទួលខុសត្រូវដូចខាងក្រោម ៈ

- ផ្តល់យោបល់ ជូនរាជរដ្ឋាភិបាលអំពីចំណែកនៃចំណូលចរន្ត ដែលត្រូវចូលរួមក្នុងមូលនិធិ
- តាមដានលំហូរធនធានទៅក្នុងមូលនិធិដែលបានមកពីជំនួយឥតសំណង និងការខ្ចី ព្រមទាំងលើកគោលដៅជូនរាជរដ្ឋាភិបាលក្នុងការគៀងគរធនធានពីក្រៅប្រទេស
- អនុម័តលើរូបមន្តបែងចែកធនធាននៃមូលនិធិ ព្រមទាំងស្នើឡើងនូវអនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូររូបមន្តដែលមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ
- អនុម័ត និងធ្វើការកែសំរួលប្រចាំឆ្នាំនូវចំណាត់ថ្នាក់នៃឃុំ សង្កាត់ ដើម្បីវិភាជន៍ដល់សមាសភាគនៃមូលនិធិ ដូចមានចែងនៅក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ
- អនុម័តផែនការប្រចាំឆ្នាំលើការបែងចែកធនធាននៃមូលនិធិដោយផ្អែកលើចំណាត់ថ្នាក់និងរូបមន្តខាងលើ
- ប្រកាសជូនឃុំ សង្កាត់នូវធនធានត្រូវទទួលបានប្រចាំឆ្នាំ និងធ្វើការព្យាករណ៍ធនធានដែលឃុំ សង្កាត់ ត្រូវទទួលបានសំរាប់រយៈពេលបីឆ្នាំទៅមុខ
- តាមដានការផ្ទេរធនធានមូលនិធិជាក់ស្តែងទៅឃុំ សង្កាត់ ប្រៀបធៀបទៅនឹងផែនការបែងចែកប្រចាំឆ្នាំ
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃមូលនិធិ

ក្រុមប្រឹក្សាភិបាលត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ក្នុងរង្វង់មួយខែ ចាប់ពីថ្ងៃនៃការបង្កើតរបស់ខ្លួន ។

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលមូលនិធិមានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| - តំណាងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាប្រធាន |
| - តំណាងក្រសួង មហាផ្ទៃ មួយរូប | ជាសមាជិក |
| - តំណាងក្រសួង ផែនការ មួយរូប | ជាសមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មួយរូប | ជាសមាជិក |
| - តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ដែលមកពីតំបន់មានកំរិតអភិវឌ្ឍន៍ខុសៗគ្នា ជ្រើសរើសដោយក្រសួងមហាផ្ទៃ ចំនួនបីរូប | ជាសមាជិក |

**មាត្រា ៦.-**

ក្រុមប្រឹក្សាភិបាលមូលនិធិមានលេខាធិការដ្ឋានមួយ ដែលត្រូវបង្កើតឡើងក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ លេខាធិការដ្ឋាននេះ មានភារៈទទួលខុសត្រូវដូចខាងក្រោម:

- សម្របសម្រួល និងធ្វើកំណត់ហេតុរាល់កិច្ចប្រជុំ ពិភាក្សារបស់ក្រុមប្រឹក្សាភិបាលមូលនិធិ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំត្រីមាសស្តីពីប្រតិបត្តិការនៃមូលនិធិ

៤

- ផ្តល់រាល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាភិបាលមូលនិធិ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានភារៈទទួលខុសត្រូវដូចខាងក្រោម:

- បញ្ជាការផ្ទេរធនធានទាំងអស់ ពីគណនីមូលនិធិទៅគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នីមួយៗ បន្ទាប់ពីបានផ្ទៀងផ្ទាត់ថាឃុំ សង្កាត់ដែលត្រូវទទួលនោះបំពេញបាននូវល័ក្ខខ័ណ្ឌនានាដូចមានចែងនៅក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ

- តាមដានការផ្ទេរមូលនិធិ និងការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់លើការប្រើប្រាស់ធនធានមូលនិធិ

- ផ្តល់ដល់ក្រុមប្រឹក្សាភិបាលមូលនិធិនូវពត៌មានលំអិតតាមកាលកំណត់ស្តីពីការផ្ទេរ និងប្រើប្រាស់ធនធាននៃមូលនិធិ ។

ក្នុងការបំពេញភារកិច្ចខាងលើ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើសកម្មភាពស្របតាមគោលការណ៍នានាដែលបានពិភាក្សាព្រមព្រៀងគ្នារបស់ក្រុមប្រឹក្សាភិបាលមូលនិធិ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ដើម្បី:

- តាមដាន និងបញ្ជាក់លើការបំពេញបានត្រឹមត្រូវនូវល័ក្ខខ័ណ្ឌប្រើប្រាស់មូលនិធិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបញ្ជាក់ក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ

- តាមដានការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រើប្រាស់ធនធានមូលនិធិ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំបទប្បញ្ញត្តិទាំងឡាយដើម្បីណែនាំដល់ អភិបាលខេត្ត ក្រុង ក្នុងការបំពេញមុខងារខាងលើ ។

## ជំពូកទី ៣
## ការធ្វើហិរញ្ញប្បទាន ការបែងចែក និង ការប្រើប្រាស់មូលនិធិ

**មាត្រា ៩.-**

អនុលោមតាមមាត្រា៧៧ នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការិតនៃការផ្ទេរពីចំណូលចរន្តនៃថវិកាជាតិទៅក្នុងគណនីមូលនិធិត្រូវគ្រោងឡើងសំរាប់ថេរៈវេលាយ៉ាងតិចចំនួន៣ឆ្នាំថវិកា។

ឆ្នាំថវិកា២០០២ ការិតនៃការផ្ទេរពីថវិការដ្ឋបានកំណត់ក្នុងមាត្រា២០ ជំពូក៥ អន្តរប្បញ្ញត្តិនៃ អនុក្រឹត្យនេះ។

ឆ្នាំថវិកា២០០៣ និង ២០០៤ ការិតនៃការផ្ទេរពីថវិការដ្ឋទៅក្នុងគណនីមូលនិធិ បានគ្រោងឡើងជាភាគរយដូចខាងក្រោម:

- ឆ្នាំថវិកា២០០៣: មិនតិចជាង២,០% (ពីរភាគរយ) នៃចំណូលចរន្ត

- ឆ្នាំថវិកា២០០៤: មិនតិចជាង២,៥% (ពីរក្បៀសប្រាំភាគរយ) នៃចំណូលចរន្ត។

រាជរដ្ឋាភិបាលត្រូវគិតគូរដល់ការបង្កើនភាគរយនេះនៅពេលមានសំណើពីក្រុមប្រឹក្សាភិបាលមូលនិធិ ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវកំណត់គោលដៅប្រចាំឆ្នាំ ដើម្បីគៀងគរការចូលរួមពីក្រៅប្រទេសទៅក្នុងមូលនិធិ ។ គណនីប្រាក់បញ្ញើមួយជារូបិយប័ណ្ណរបស់មូលនិធិឃុំ សង្កាត់ ត្រូវបានបើកនៅធនាគារជាតិនៃកម្ពុជា ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទទួលធនធានពីជំនួយឥតសំណង និងការខ្ចីដែលម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាចូលរួម ។

ចំណូលរបស់មូលនិធិឃុំ សង្កាត់ក្នុងគណនីនៅធនាគារជាតិនៃកម្ពុជា ត្រូវផ្ទេរជាប្រាក់រៀលទៅគណនីរបស់មូលនិធិនៅរតនាគារជាតិនៅពេលណាដែលត្រូវការ ។

**មាត្រា ១១.-**

ចំណែកនៃធនធានមូលនិធិសរុបដែលអាចផ្ទេរទៅឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយរូបមន្តមួយ ។ រូបមន្តនេះត្រូវស្របទៅនឹងគោលបំណងនៃមូលនិធិ ដូចមានចែងនៅក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវអនុម័តរូបមន្តនិងប្រកាសពីចំនួនធនធានដែលឃុំ សង្កាត់នីមួយៗនឹងទទួលបានសំរាប់ឆ្នាំបន្ទាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែតុលា នៃឆ្នាំថវិកា ។

**មាត្រា ១២.-**

ធនធានសរុបនៃមូលនិធិត្រូវបានបែងចែកជាពីរសមាសភាគដូចខាងក្រោម :

- សមាសភាគរដ្ឋបាលទូទៅ មិនត្រូវច្រើនជាង ១ ភាគ ៣ នៃធនធានមូលនិធិសរុប
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន មិនត្រូវតិចជាង ២ ភាគ ៣ នៃធនធានមូលនិធិសរុប ។

ក្រុមប្រឹក្សាភិបាលមូលនិធិ ត្រូវកំណត់វិធីក្នុងការបែងចែកធនធានមូលនិធិសរុបដល់សមាសភាគទាំងពីរតាមកំរិតកំណត់ខាងលើ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំចំណាត់ថ្នាក់ឃុំ សង្កាត់ ជា ២ ប្រភេទ:

ប្រភេទទី១: រួមមានឃុំ សង្កាត់ដែលក្រុមប្រឹក្សាភិបាលមូលនិធិយល់ឃើញថាមានសមត្ថភាព និងលទ្ធភាពក្នុងការប្រើប្រាស់ធនធានមូលនិធិដែលបានផ្ទេរសំរាប់ចំណាយអភិវឌ្ឍន៍ល្អប្រសើរ និងមានប្រសិទ្ធភាព ។

ប្រភេទទី២: រួមមាន ឃុំ សង្កាត់ដែលគ្មាននៅក្នុងប្រភេទទី១ ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំ និងអនុម័តនូវផែនការពហុឆ្នាំដើម្បីបង្កើនជាបណ្តើរៗចំនួនឃុំ សង្កាត់ទៅក្នុងប្រភេទទី១ ។

ផ្អែកលើផែនការខាងលើ និងអោយបានមុនថ្ងៃទី០១ខែតុលារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវពិនិត្យចំនួនឃុំ សង្កាត់ដែលមានលក្ខណសម្បត្តិសមស្របគួរបញ្ចូលក្នុងប្រភេទទី១ ។

-5-

**មាត្រា ១៤.-**

ធនធានទាំងឡាយ នៃសមាសភាគទាំងពីររបស់មូលនិធិត្រូវបានបែងចែក និង ប្រើប្រាស់តាមការកំណត់ខាងក្រោម:

ក) ធនធាននៃសមាសភាគរដ្ឋបាលទូទៅ

- អាចប្រើប្រាស់ដោយឃុំ សង្កាត់នៅក្នុងប្រភេទទី១ និងប្រភេទទី២
- ត្រូវបែងចែកតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ
- អាចអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចំណាយប្រតិបត្តិការ ឬវិនិយោគផ្នែករដ្ឋបាលដែលសមស្របដូចបានកំណត់នៅក្នុងមាត្រា ១៥ នៃអនុក្រឹត្យនេះ ។

ខ) ធនធាន នៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន

- អាចប្រើប្រាស់បានតែក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងប្រភេទទី១
- ត្រូវគណនាចេញជាបីចំណែក: ចំណែកស្មើគ្នាជាមូលដ្ឋាន ចំណែកសមាមាត្រទៅនឹងប្រជាពលរដ្ឋ និងចំណែកសមាមាត្រទៅនឹងសន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ
- អនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះតែលើចំណាយអភិវឌ្ឍន៍ ដូចបានកំណត់នៅក្នុងមាត្រា១៥ នៃអនុក្រឹត្យនេះ ។

ក្រសួងផែនការត្រូវផ្តល់អោយក្រុមប្រឹក្សាភិបាលមូលនិធិអោយបានមុនថ្ងៃទី០១ ខែកញ្ញា នៃឆ្នាំនិមួយៗនូវការប៉ាន់ស្មានចុងក្រោយអំពី :

- ចំនួនប្រជាពលរដ្ឋសរុប នៃ ឃុំ សង្កាត់ នីមួយៗ
- សន្ទស្សន៍ភាពក្រីក្រនៃឃុំ សង្កាត់នីមួយៗ

**មាត្រា ១៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ថវិកាផ្ទេរពីមូលនិធិឃុំ សង្កាត់សំរាប់ចំណាយមួយផ្នែកឬ ទាំងស្រុងលើវិនិយោគ និងប្រតិបត្តិការ ដែលឆ្លុះបញ្ចាំងនៅក្នុងថវិកាដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងមិនផ្ទុយទៅនឹងច្បាប់ និងលិខិតបទដ្ឋានទាំងឡាយជាធរមាន ។

ការចំណាយរដ្ឋបាល គឺជាចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តនីភារកិច្ចរដ្ឋបាលទូទៅរបស់ខ្លួន ។ ចំណាយនេះរួមមាន :

- ប្រាក់បំណាច់ សំរាប់ក្រុមប្រឹក្សា ឃុំ សង្កាត់
- បៀវត្សមន្ត្រី ឃុំ សង្កាត់ និង ចំណាយផ្សេងៗដល់មន្ត្រី បុគ្គលិកទាំងនោះ
- ការទិញ ឬ ការជួលទីតាំងសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់
- សម្ភារៈ និង ឧបករណ៍ការិយាល័យឬ មធ្យោបាយសំភារៈរដ្ឋបាល សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់

៦

- ការជួសជុល និង ការថែទាំមធ្យោបាយសំភារៈរដ្ឋបាល
- ថ្លៃប្រើប្រាស់ទឹក និង អគ្គិសនី
- ទិញ ឬ ជួលយានជំនិះ
- ប្រេងឥន្ធនៈ ប្រេងរំអិល និងការ ថែទាំយានជំនិះ
- ចំណាយផ្សេងៗ

ចំណាយអភិវឌ្ឍន៍គឺជាចំណាយប្រតិបត្តិការ និង ចំណាយវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន (លើកលែងមធ្យោបាយសំភារៈរដ្ឋបាល) និងការផ្តល់សេវាសេដ្ឋកិច្ចសង្គមនៅឃុំ សង្កាត់ (លើកលែង រដ្ឋបាល) ។ ចំណាយទាំងនោះរួមមាន :

- ការអង្កេត គំនូសប្លង់ ការសាងសង់ ការជួសជុល និង ការថែទាំផ្លូវ ផ្សារ មណ្ឌលសុខភាព សាលារៀន មជ្ឈមណ្ឌល សហគមន៍ សំណង់ប្រព័ន្ធធារាសាស្ត្រ ឃ្លាំងផ្ទុកកសិផល ប្រព័ន្ធផ្គត់ផ្គង់ទឹក និង ថាមពល និង ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គម ផ្សេងទៀត ។

- ចំណាយលើមន្ត្រីបុគ្គលិកនិងចំណាយចរន្តដែលពាក់ព័ន្ធនឹងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវា

- ចំណាយគាំទ្រកម្មវិធីអភិវឌ្ឍន៍សហគមន៍ ដែលចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន និងអង្គការជួយសហគមន៍ រួមបញ្ចូលនូវយុទ្ធនាការផ្តល់ពត៌មាន និង អប់រំសំរាប់ស្ត្រី និង យុវជននៅមូលដ្ឋាន ការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីដទៃដែលមានឥទ្ធិពលដល់សុខុមាលភាពសង្គម និងប្រជាពលរដ្ឋនៅមូលដ្ឋាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសេចក្តីណែនាំលំអិតមួយ ដោយផ្សារភ្ជាប់ទៅនឹងបទបញ្ញត្តិស្តីពីថវិកាឃុំ សង្កាត់ ដើម្បីធ្វើយ៉ាងណាអោយប្រភេទរដ្ឋបាលនិងអភិវឌ្ឍន៍មានភាពរលូនទៅនឹងចំណាត់ថ្នាក់ចំណាយនៅក្នុងថវិកា ។

## ជំពូកទី ៤
## នីតិវិធីនៃការផ្ទេរ និង លក្ខខ័ណ្ឌទទួលបានធនធានមូលនិធិ

**មាត្រា ១៦.-**

ឃុំ សង្កាត់ទាំងអស់ត្រូវមានគណនីប្រាក់បញ្ញើមួយនៅរតនាគារខេត្ត ក្រុង ឬ នៅធនាគារពាណិជ្ជណាមួយដែលមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

អនុលោមតាមមាត្រា៧នៃអនុក្រឹត្យនេះ និងតាមសំណើរបស់ក្រសួងមហាផ្ទៃ រតនាគារជាតិត្រូវផ្ទេរថវិកាវិភាជន៍ដែលបានអនុម័តប្រចាំឆ្នាំទៅគណនីរបស់ឃុំ សង្កាត់នីមួយៗ នៅរតនាគារខេត្ត ក្រុង ឬ ធនាគារពាណិជ្ជ ។

ថវិកាផ្ទេរប្រចាំឆ្នាំត្រូវធ្វើឡើងជាបីលើកៈ ការផ្ទេរលើកទី១គឺ ៥០%(ហាសិបភាគរយ) នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ០១ ខែមីនា លើកទី២គឺ ៣០%(សាមសិបភាគរយ)នៃចំនួនផ្ទេរសរុប អោយបានមុនថ្ងៃទី ០១ខែមិថុនា និងលើកទី៣ ចំនួននៅសល់ ២០%(ម្ភៃភាគរយ) ត្រូវផ្ទេរអោយបានមុនថ្ងៃទី ០១ ខែកញ្ញា។

**មាត្រា ១៧.-**

ដើម្បីទទួលបានការផ្ទេរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជាក់ថាខ្លួនបានៈ

- អនុវត្តតាមវិធីចូលរួមក្នុងដំណើរការ ធ្វើផែនការ ថវិកា និង ការងារប្រតិបត្តិ
- បំពេញរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍ថវិកា និង ផែនការអភិវឌ្ឍន៍របស់ខ្លួន ។
- ប្រមូលទុនចូលរួមរបស់មូលដ្ឋាន ព្រមទាំងធនធានដទៃទៀតរបស់មូលដ្ឋានដើម្បីបំពេញបន្ថែមលើការផ្ទេរពីមូលនិធិ នៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ក្នុងរយៈពេល ២០ ថ្ងៃ ពីថ្ងៃទទួលបានពាក្យសុំផ្ទេរថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុង ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវៈ

- ផ្ទៀងផ្ទាត់លើការអនុវត្តន៍ល័ក្ខខ័ណ្ឌទាំងឡាយដើម្បីទទួលបានធនធានមូលនិធិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ ទៅក្រសួងមហាផ្ទៃ លើការបំពេញបានសព្វគ្រប់នៃការផ្ទេរធនធាន

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់មិនបំពេញបានចំពោះល័ក្ខខ័ណ្ឌ អភិបាលខេត្ត ក្រុងត្រូវជួយផ្តល់យោបល់ និងណែនាំ សកម្មភាព កែតំរូវ និងផ្តល់ជំនួយបច្ចេកទេសចាំបាច់ ។ បន្ទាប់មកអភិបាលខេត្ត ក្រុង ត្រូវស្នើយោបល់ទៅក្រសួងមហាផ្ទៃ ដើម្បីផ្អាកការផ្ទេរសិនរហូតដល់កង្វះខាតដែលស្នើអោយកែតំរូវខាងលើត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់បំពេញតាមត្រឹមត្រូវ។

ក្នុងករណីមានបាតុភាពមិនចុះសំរុងគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់និងអភិបាលខេត្ត ក្រុងនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនបញ្ហានេះទៅក្រុមប្រឹក្សាភិបាលមូលនិធិដើម្បីពិនិត្យ និងសំរេច ។ ការសំរេចរបស់ក្រុមប្រឹក្សាភិបាលមូលនិធិចាត់ទុកជា សេចក្តីសំរេចចុងក្រោយបង្អស់ ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**មាត្រា ១៨.-**

ក្នុងពេលដែលក្រុមប្រឹក្សាភិបាលមូលនិធិមិនទាន់បង្កើតឡើង គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវធានាអនុវត្តមាត្រា ៤ នៃអនុក្រឹត្យនេះ ដោយមានអនុគណៈកម្មការកិច្ចការហិរញ្ញវត្ថុជាជំនួយការ ។

**មាត្រា១៩.-**

ក្នុងអាណត្តិរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវធ្វើអនុសាសន៍ និងរាយការណ៍ជាទៀងទាត់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្តីពីប្រតិបត្តិការរបស់មូលនិធិ ។ បទប្បញ្ញត្តិ ព្រមទាំងសេចក្តីណែនាំ ឬបទបញ្ជាទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការ របស់មូលនិធិត្រូវដាក់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ពិនិត្យសំរេច ។

ក្រុមប្រឹក្សាភិបាលមូលនិធិត្រូវរៀបចំ និងដាក់ជូន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ អនុម័តផែនការពហុឆ្នាំ ក្នុងរយៈពេល៦ខែបន្ទាប់ពីត្រូវបានបង្កើតឡើង ដើម្បីបង្កើនជាបណ្តើរៗនូវចំនួនឃុំទៅក្នុងប្រភេទទី១ ។

**មាត្រា ២០.-**

សំរាប់ឆ្នាំថវិកា២០០២ ការផ្ទេរពីថវិកាជាតិទៅក្នុងមូលនិធិឃុំ សង្កាត់ មានចំនួន ២០.០០០.០០០.០០០៛ (ម្ភៃពាន់លានរៀល) ។

**មាត្រា ២១.-**

ឃុំ សង្កាត់ដែលត្រូវបញ្ចូលទៅក្នុងប្រភេទទី១ ក្នុងឆ្នាំថវិកា ២០០២ គឺឃុំ សង្កាត់ទាំងឡាយណាដែលមានផែនការអភិវឌ្ឍន៍របស់ខ្លួន មានសមត្ថភាព លទ្ធភាព ក្នុងការប្រើប្រាស់មូលនិធិសំរាប់អភិវឌ្ឍន៍បានល្អប្រសើរ និងមានប្រភពហិរញ្ញប្បទានជាក់លាក់ ។

**មាត្រា ២២.-**

ឆ្នាំថវិកា២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានទទួលការផ្ទេរមូលនិធិលើកទី១ និងលើកទី២ ដោយមិនបាច់បំពេញល័ក្ខខ័ណ្ឌ ។ ក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំ និងទំរង់របាយការណ៍សំរាប់អនុវត្តការផ្ទេរលើកទី៣ អោយបានមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០២ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ អភិបាលខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

**ស ខេង** **យូ ហុកគ្រី**

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**គាត ឈន់**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*